**STREAM** ឆ្នាំទី២ លេខ ៤ ខែ តុលា-ធ្នូ ២០០៤

**Support to Regional Aquatic Resources Management**
**គំរោងជួយគ្រប់គ្រងធនធានវារីជាតក្នុងតំបន់**

# ទស្សនាវដ្តី STREAM

## ទំនាក់ទំនង និង រៀនសូត្រពីការចិញ្ចឹមជីវិតរបស់អ្នកនេសាទ និង កសិករ

គំរោងត្រូវបានការជួយឧបត្ថម្ភដោយ AusAID, DFID, FAO, NACA និង VSO

## មាតិកា

បទពិសោធក្នុងការចងក្រងជាក្រុមនៅក្នុងភូមិ Jabarrah រដ្ឋ West Bengal នៃប្រទេសឥណ្ឌា ១

*Amar Prasad, Virendra Singh, Binay Sahay* និង *Gautum Dutta*

វារីវប្បកម្មដោយក្រុមជួយខ្លួនឯងនៅតំបន់ជនបទនៃរដ្ឋ West Bengal ៣

*Satyendra Tripathi, Graham Haylor and William Savage* ដោយពិគ្រោះយោបល់ជាមួយ លោក *Jagdish Gangwar,Virendra Singh, Gautam Dutta* និង *Prabhat Pathak*

បទពិសោធសំរាប់ភូមិ Fulwar Toli ដែលបានទស្សនកិច្ចនៅភូមិ Jabarrah ៦

*Bhim Nayak* និង *Rubu Mukherjee*

ការធ្វើអន្តរាគមន៍ដល់ជីវភាពរស់នៅដោយទីភ្នាក់ងារអភិវឌ្ឍន៏កសិករចិញ្ចឹមត្រី: ការងារទទួលបានជោគជ័យពីស្រុក Mayurbhanj នៃរដ្ឋ Orissa ៨

*G B Parida*

ស្វែងយល់ពីធនធាននៃការចិញ្ចឹមជីវិតតាមរយៈការវាយតំលៃជនបទដោយឆាប់រហ័ស (PRA) ដើម្បីលុបបំបាត់ភាពអត់ឃ្លាន ១១

*Binay Sahay*

វិធានចាត់ថ្នាក់ភាពក្រីក្រក្នុង PRA :បទពិសោធពីគំរោង EIRFP ក្នុងការលើកឡើងពីបញ្ហាភាពងាយរងគ្រោះ ១៤

*Binay Sahay*

អំពីទស្សនាវដ្តី STREAM ១៧

អំពីគំរោង STREAM ១៩

## **កំណត់ចំណាំៈ**

ទស្សនាវដ្តីរបស់ STREAM ឆ្នាំទី២ លេខ ៤ នេះគឺជារឿងរ៉ាវទាក់ទងនិងប្រទេសឥណ្ឌាដែលគំរោងSTREAM មានដៃគូរនៅភាគខាងកើតនៃប្រទេសនេះ។ ក្នុងនោះដៃគូររួមមានអង្គការមិនមែនរដ្ឋាភិបាលមួយរបស់ប្រទេសឥណ្ឌាមានឈ្មោះថា Gramin Vikas Trust (GVT) សហគមន៏ជនជាតិភាគតិច និង នាយកដ្ឋានជលផលនៅក្នុងរដ្ឋ៣ដែល STREAM ធ្វើការជាមួយដូចជារដ្ឋ Jharkhand, Orissa និង West Bengal។

អត្ថបទ ៣ តំបូងនិងលើកឡើងពីរឿងរ៉ាវទាក់ទងនឹងភូមិ Jabarrah និង ភូមិដ៏ទៃទៀតនៅក្នុងស្រុក Purulia នៃរដ្ឋ West Bengal។ សហការីមកពី GVT បានរៀបរាប់ពីរបៀបដែលក្រុមជួយខ្លួនឯងត្រូវបានគេបង្កើតឡើង ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងក្នុងតំណាក់កាលអភិវឌ្ឍន៍តំបូង។ បន្ទាប់មកសហការីមកពី STREAM និង សរសេរពីអ្វីដែលគេបានរៀនពីជោគជ័យនៅភូមិ Jabarrah ក្នុងពេលទស្សនកិច្ចក្នុងរយៈពេល ២-៣ ឆ្នាំចុងក្រោយ។ តំណាងមកពីភូមិមួយមកពីរដ្ឋជិតខាងរដ្ឋ Jharkhand បានរៀបរាប់ពីគំនិតផ្តួចផ្តើមដែលគាត់បានធ្វើជាមួយសហគមន៏របស់គាត់ បន្ទាប់ពីគាត់បានទៅទស្សនកិច្ចនៅភូមិ Jabarrah ។

បន្ទាប់ទៅនេះយើងទៅពិនិត្យមើលនៅរដ្ឋ Orissa មន្ត្រីនៃទីភ្នាក់ងារអភិវឌ្ឍន៏កសិករចិញ្ចឹមត្រីនៅស្រុក Muyurbhanj បានរៀបរាប់ពីកសិករចិញ្ចឹមត្រីម្នាក់បានទទួលផលប្រយោជពីការជួយឧបត្ថម្ភរបស់រដ្ឋាភិបាល។ អត្ថបទពីរចុងក្រោយទាក់ទងនឹងរបៀបប្រើប្រាស់យុទ្ធសាស្ត្រចិញ្ចឹមជីវិត និង វិធាន PRA ដោយ GVT នៅក្នុងការងាររបស់គេជាមួយសហគមន៏ជនបទ។

យើងសូមថ្លែងអំណរគុណដល់ដៃគូររបស់យើងនៅប្រទេសឥណ្ឌា ហើយជាពិសេសសូមថ្លែងអំណរគុណដល់ GVT ដែលបានផ្តល់ការិយាល័យដល់ STREAM នៅ Ranchi និង Jharkhand កន្លែងដែលលោក Rubu Makherjee ជាអ្នកគ្រប់គ្រងមណ្ឌលទំនាក់ទំនង ធ្វើការ។ ក៏សូមថ្លែងអំណរគុណដល់លោក Rubu ដែលបានខិតខំប្រឹងប្រែងប្រមូលផ្តុំ ចងក្រង ហើយដាក់នៅក្នុងទស្សនាវដ្តីលេខនេះ។

សូមលោកអ្នកអានដោយក្តីរីករាយ

លោក Graham Haylor នាយកគំរោង STREAM
លោក William Savage បណ្ណាធិការទស្សនាវដ្តី STREAM

## បទពិសោធក្នុងការចងក្រងជាក្រុមនៅក្នុងភូមិ Jabarrah រដ្ឋ West Bengal នៃប្រទេសឥណ្ឌា

*Amar Prasad, Virendra Singh, Binay Sahay* និង *Gautum Dutta*

**មុនពេល** GVT **មកដល់**

Jabarrah គឺជាកំរងភូមិមួយស្ថិតនៅក្នុងស្រុក Purulia រដ្ឋ West Bengal ។ ប្រហែល ៤៨% នៃផ្ទៃដីនៅក្នុងភូមិគឺគ្មានជីវជាតិ ។ គ្រោះរាំងស្ងួត និង ភ្លៀងមិនទៀតទាត់គឺជារឿងធម្មតានៅក្នុងភូមិ ។ ភាគច្រើននៃអ្នកភូមិគឺជាកម្មករដើររកការងារធ្វើនៅក្រៅភូមិ ។ ភាគច្រើននៃប្រជាជននៅក្នុងភូមិគឺជាជនជាតិភាគតិច ។

រហូតដល់ឆ្នាំ ១៩៩៤ មុនពេលគំរោងកសិកម្មពឹងផ្អែកទឹកភ្លៀងនៅភាគខាងកើតប្រទេសឥណ្ឌា (EIRFP) មកដល់ អ្នកភូមិមិនដែលស្គាល់ និង ដឹងពីរបៀបចិញ្ចឹមត្រី ឬក៏ធ្វើផែនការសំរាប់អភិវឌ្ឍន៍ភូមិទេ ។ មានកសិករតែ ២-៣ នាក់ប៉ុណ្ណោះ ដែលចិញ្ចឹមត្រីដោយប្រើបច្ចេកទេសបុរាណ ហើយទទួលបានប្រាក់ចំណូលទាបពីការចិញ្ចឹម ។

**យុទ្ធសាស្ត្រចូលរួមរបស់គំរោង** EIRFP



ដោយប្រើប្រាស់យុទ្ធសាស្ត្រអភិវឌ្ឍន៍ដោយមានការចូលរួម គំរោង EIRFP បានចាប់ផ្តើមលើកកំពស់ការចិញ្ចឹមជីវិតរបស់ជនជាតិ និង ជនក្រីក្រដោយការចូលរួមយ៉ាងសកម្មរបស់ពួកគេ ។ គំរោងបានចាប់ផ្តើមធ្វើការនៅភូមិ Jabarrah ដែលជា ភូមិក្រីក្រ មួយនៅរដ្ឋ West Bengal ដើម្បីរៀបចំសហគមន៍ឱ្យរួបរួមគ្នាដើម្បីអភិវឌ្ឍន៍ ។ សហគមន៍បានបង្កើតក្រុមបុរសពីរក្រុមដែលមានឈ្មោះថា Padma Lochan និង Nabodaya ដោយមានសមាជិក ៩ និង ១០ នាក់ និង ក្រុមស្ត្រី ២ ក្រុមដែលមានឈ្មោះថា Mahamaya និង Shilawati ដែលមានសមាជិក ១០ នាក់ក្នុងមួយក្រុម១ ។ ក្រុមផ្សេងទៀតមានឈ្មោះថា Maa Santoshi ត្រូវ បានបង្កើតនៅឆ្នាំ ១៩៩៧ ។

សមាជិកសហគមន៍ជាបណ្តើរ១បានដឹងពីសារៈសំខាន់នៃការចងក្រងជាក្រុម ដែលជាហេតុធ្វើឱ្យពួកគេកាន់តែមានភាពជឿជាក់ ។ ពួកគេមិនត្រឹមតែបើកគណនីនៅធនាគារនៅក្បែរនោះទេ ប៉ុន្តែពួកគេបានបង្កើតបទដ្ឋានសំរាប់ដំណើរការក្រុមទៀតផង ។ ពួកគេថែមទាំងបានសំរេចបង្កើតគណៈកម្មការកណ្តាលដែលមានឈ្មោះថា Jote Solah Anna ដើម្បីត្រួតពិនិត្យសកម្មភាពក្រុមទាំង ៥ ។

**ការកសាងសមត្ថភាពរបស់សមាជិកក្រុម**

គម្រោង EIRFP បានគិតថាដើម្បីអភិវឌ្ឍន៍ភូមិ ត្រូវកសាងសមត្ថភាព និង ជំនាញរបស់សមាជិកក្រុម ។ គម្រោងក៏បានរកអ្នកងទៀតដែលហៅថា Jankars (គ្រូបង្គោល) ដែលមានជំនាញ និង ចាប់អារម្មណ៍លើមុខវិជ្ជា ឬក៏សកម្មភាពផ្សេង១ ។ ការចុះបំពាក់បំប៉នផ្ទាល់នៅនឹងកន្លែង និង អនុវត្តផ្ទាល់ ត្រូវបានគេធ្វើឡើងដើម្បីលើកកំពស់ជំនាញរបស់ពួកគេ ។ Jankars ត្រូវបានគេបំពាក់

បំប៉នលើមុខវិជ្ជាមួយចំនួនដូចជា ការចងក្រង និង គ្រប់គ្រងក្រុម ការសន្សំ និង ឥណទាន ការគ្រប់គ្រងមូលនិធិរបស់ក្រុម ការធ្វើកសិកម្ម វារីវប្បកម្ម ការអភិរក្សព្រៃឈើ ដី និង ទឹក ការចិញ្ចឹមសត្វ និង សកម្មភាពរកប្រាក់ចំណូលផ្សេងៗទៀត សំរាប់គ្រួសារគ្មានដីធ្លី (ឧទាហរណ៍ ដូចជាធ្វើស្មុក វេញខ្សែ និង ចិញ្ចឹមមាន់ ទា)។

ទាក់ទងនឹងការចិញ្ចឹមត្រី Jankars ត្រូវបានគេបំពាក់បំប៉នលើ ការព្រលែងកូនត្រី ការគ្រប់គ្រងស្រះ និង ការពិនិត្យគុណភាពទឹក។ អ្នកចូលរួមបានរៀបរាប់ថា ពួកគេមិនត្រឹមតែមានការជឿជាក់លើខ្លួនឯងប៉ុណ្ណោះទេ ប៉ុន្តែពួកគេអាចយកចំណេះដឹងដែលបានរៀនយកទៅអនុវត្តយ៉ាងមានប្រសិទ្ធិភាព និង ទាន់ពេលវេលាទៀតផង។

**សកម្មភាពចិញ្ចឹមត្រីនៅក្នុងភូមិ**



ក្រុមបានរកមើលស្រះនៅក្នុងភូមិដែលអាចចិញ្ចឹមត្រីបាន ពួកគេបានទិញស្រះពីម្ចាស់ដី ដោយមួយគ្រួសារចំណាយ ៣០០ រូពី ឬ ប្រហែល ៦ ដុល្លាអាមេរិច និង ពីមូលនិធិរបស់ក្រុមតាមរយៈប្រាក់ចំណូលផ្សេងៗ។ ពួកគេបានចាប់ផ្តើមចិញ្ចឹមត្រីដោយបច្ចេកទេសសមស្រប និង ទទួលបានការឧបត្ថម្ភពីគម្រោង EIRFP ជាកូនត្រី និង ចំណី។ ដោយចាប់ផ្តើមពីការងារតូច ក្នុងរយៈពេល ២ ឆ្នាំ ក្រុមបានពង្រីកកម្មវិធីចិញ្ចឹមត្រីកាន់តែធំ ឥឡូវនេះពួកគេបានដំណើរការដោយជោគជ័យ និង មានប្រសិទ្ធិភាព។សមាជិកក្រុមបានប្រមូលផលត្រីរួមគ្នា ប៉ុន្តែការលក់ដូរគឺធ្វើឡើងរៀងៗខ្លួន ដោយម្នាក់ៗត្រូវទិញត្រីពីក្រុម ហើយលក់ នៅតំបន់ជិតខាង។ អ្នកចិញ្ចឹមត្រីស្ត្រីម្នាក់ឈ្មោះ Thanda Mahato តែងតែទិញត្រីពីក្រុម ហើយអាចរកប្រាក់ចំណូលបាន ១០០-១៥០ រូពីក្នុងមួយថ្ងៃ ហើយលក់៣-៤ ថ្ងៃ/សប្តាហ៍។ នាងអាចគ្រប់គ្រងការចាយវាយនៅក្នុងគ្រួសារ ហើយសល់លុយខ្លះដាក់នៅ ធនាគារ។

**ទំនាក់ទំនងជាមួយរដ្ឋាភិបាល និង អង្គការមិនមែនរដ្ឋាភិបាលៈ ឱកាសដើម្បីធ្វើការផ្លាស់ប្តូរ**

ភាពខ្លាំងនៃក្រុម ជាបណ្តើរៗត្រូវបានបង្កើន ហើយឥឡូវនេះមានតំណាង ១៤ ក្រុមនៅក្នុងគណៈកម្មការកណ្តាល។ ក្នុងកំឡុងពេលបំពាក់បំប៉ន កសិករបានដឹងពីមន្ត្រីជលផលថា រដ្ឋាភិបាលបានផ្តល់សម្ភារៈផ្សេងៗតាមរយៈកម្មវិធីជលផល។ សមាជិកសហគមន៍បានស្នើដល់អាជ្ញាធរមូលដ្ឋានដើម្បីស្តារស្រះហើយពួកគេក៏ទទួលបាននូវប្រាក់ចំនួន ១១,០០០ រូពី។ ពួកគេក៏ទទួលបាននូវកូនត្រី មង និង សម្ភារៈផ្សេងៗផងដែរ។កិច្ចខិតខំរបស់ GVT គឺផ្តោតលើការកសាងធនធានសង្គម និង មនុស្សដើម្បីឈានទៅរកការលើកកំពស់ជីវភាពរស់នៅរបស់ប្រជាជននៅក្នុងភូមិ និង ផ្តល់ជាឧទាហរណ៍សំរាប់ភូមិជិតខាង។ សមាជិកក្រុមបានកសាងផែនការដើម្បីអភិវឌ្ឍន៍ភូមិរបស់គេដោយមានការយល់ដឹង និង ទស្សនវិស័យច្បាស់លាស់។ ពួកគេក៏ទទួលស្គាល់ពីតួនាទីរបស់អង្គការមិនមែនរដ្ឋាភិបាល ដូចជា GVT ក្នុងការផ្តល់នូវទិសដៅសំរាប់អភិវឌ្ឍន៍។

*Amar Prasad, Virendra Singh, Binay Sahay and Gautum Dutta* ធ្វើការនៅធនាគារ *Gramin Vikas Trust (GVT).* មុខតំណែងរបស់គេគឺនាយកធនាគារ អ្នកគ្រប់គ្រងគម្រោង អ្នកជំនាញការខាងការអភិវឌ្ឍន៍សង្គម និង អ្នកជំនាញខាងវារីវប្បកម្ម ។យើងអាចទាក់ទងតាមរយៈអ៊ីមែល <rch_gvteirfp@sancharnet.in>.

# វារីវប្បកម្មដោយក្រុមជួយខ្លួនឯងនៅតំបន់ជនបទនៃរដ្ឋ West Bengal

*Satyendra Tripathi, Graham Haylor and William Savage* ដោយពិគ្រោះយោបល់ជាមួយ

លោក *Jagdish Gangwar,Virendra Singh, Gautam Dutta* និង *Prabhat Pathak*

**ត្រលប់ទៅភូមិ** Jabarrah **វិញ**

ក្នុងឆ្នាំ ១៩៩៦ បណ្ឌិត Satyendra Tripathi ជាអ្នកជំនាញការអភិវឌ្ឍន៍វារីវប្បកម្មរបស់គំរោង EIRFP និងបណ្ឌិត Graham Haylor បានទៅទស្សនកិច្ចនៅភូមិ Jabarrah ក្នុងរដ្ឋ West Bengal។ នៅពេលនោះ ៦០%នៃអ្នកភូមិគ្មានអាហារហូបគ្រប់គ្រាន់ពេញមួយឆ្នាំ ហើយភាគច្រើនពួកគេតែងតែស៊ីឈ្នួលគេដោយតំលៃថោកៗ។ ប្រហែលមួយភាគបួននៃគ្រួសារអ្នកភូមិជំពាក់បំណុលគេ ដោយសារខ្វះលុយទិញម្ហូបអាហារ និង ថ្នាំពេទ្យ។ ក្មេងៗត្រូវដើរទៅរៀន ៤ គីឡូម៉ែត្រ។ ទោះបីជួបគ្រោះទឹកជំនន់ និង រាំងស្ងួត ៣ ភាគ ៤ នៃគ្រួសារទាំងអស់ធ្វើស្រែ ហើយអ្នកខ្លះទៀតស៊ីឈ្នួលធ្វើស្រែ ធ្វើតដ្ឋ និង លេងភ្លេងការ។ មានតែ ២ ភាគ ៣ នៃបុរស និង ១ ភាគ ៣ នៃស្ត្រីអាចអានអក្សរបាន។

ចាប់តាំងពីឆ្នាំ ១៩៩៥ សារជីវកម្មជីរបស់ប្រទេសឥណ្ឌា សារជីវកម្ម Krishak Bharti រួមជាមួយដៃគូរនាយកដ្ឋានអភិវឌ្ឍន៍អន្តរជាតិនៃចក្រភពអង់គ្លេស បានបំផុសប្រជាជនឱ្យចងក្រងជាក្រុមដើម្បីធ្វើផែនការអភិវឌ្ឍន៍ តាមរយៈការកសាងធនធានសង្គម។ ដូចលោក Viranda Singh មានប្រសាសន៍ថា " ធនធានសង្គមត្រូវបានកសាងឡើងដោយ និង នៅក្នុងសហគមន៍ដោយមានការលើកទឹកចិត្តខ្ពស់ និង មានយុទ្ធនាការលើកកំពស់ការយល់ដឹងពីអ្នករៀបចំសហគមន៍។

នៅខែកញ្ញា ២០០៣ យើងមានឱកាសត្រលប់ទៅភូមិ Jabarrah វិញជាមួយ GVT ជា NGO ដែលជាប់ពាក់ពន្ធ័ជាមួយគំរោង EIRFP ហើយលោក Ajit Banerjeeជាអ្នកគ្រប់គ្រងសាខាធនាគារ Maubhum Gramin នៅក្បែរ Ludhurka។ ដោយចាប់ផ្ដើមពី ៣ ក្រុម រហូតពង្រីកបានជាង ៤០ ក្រុមហើយមានការចាត់ចែងបានល្អ មិនត្រឹមតែនៅក្នុងភូមិ Jabarrah ទេ ប៉ុន្តែនៅភូមិក្បែរនោះផងដែរ។

**ប្រពន្ធ័ Doba** ( ស្រះដក់ទឹកតាមរដូវ)

ដូចជាគ្រួសារក្រីក្រនៅតំបន់ជនបទឯទៀតៗដែរ សមាជិកក្រុមគ្មានស្រះធំ ដើម្បីចិញ្ចឹមត្រី ដូចដែលបានផ្សព្វផ្សាយដោយនាយកដ្ឋានជលផលទេ។ នៅតំបន់ដែលគ្មានប្រពន្ធ័ស្រោចស្រព "ទឹកគឺជាតម្រូវការចាំបាច់ មានតែគ្រួសារអ្នកមានទេដែលមានស្រះធំ " ។ ក្រុមជួយខ្លួនឯងបំប៉នកូនត្រីនៅក្នុងស្រះតូចៗ បន្ទាប់មកយកទៅចិញ្ចឹមនៅស្រះធំ។ គំនិតនេះគឺផ្ដួចផ្ដើមឡើងដោយគម្រោង EIRFP ហើយត្រូវបានគេឱ្យឈ្មោះថា ប្រពន្ធ័ Doba ។ លោក Shamlal ជាអ្នកសំរបសំរួលឱ្យ GVT នៅរដ្ឋ West Bengalបាននិយាយថា



ការបំប៉នកូនត្រីនៅតាមស្រះតូចៗ

ការស្រាវជ្រាវពីជំរើសនៃការចិញ្ចឹមត្រីរបស់ប្រជាជន និង ការប្រើប្រាស់ប្រពន្ធ័ Doba ត្រូវបានធ្វើឡើងដោយសហការជាមួយគម្រោងរបស់ DFID ដែលមានឈ្មោះថា "ធ្វើវារីវប្បកម្មចំរុះជាមួយប្រពន្ធ័កសិកម្មនៅភាគខាងកើតប្រទេសឥណ្ឌា" ពីឆ្នាំ ១៩៩៦ ដល់ ២០០០។ ការដើររាំតាមផ្លូវដែលមានឈ្មោះថា "ស្រះចិញ្ចឹមត្រីតូចៗ" សរសេរឡើងដោយអ្នកភូមិម្នាក់ឈ្មោះ Rakesh Rahman ដោយបង្ហាញពីការរស់នៅរបស់អ្នកភូមិ និង សក្តានុពលនៃសកម្មភាពនៅរដូវដែលមិនសូវមានការងារធ្វើនៅក្នុងភូមិ គឺការបំប៉នត្រីនៅក្នុងស្រះតូចៗ ជំនួសឱ្យការដើររកការងារធ្វើនៅក្រៅភូមិ។ លោក Nityo បានរៀបរាប់តើប្រពន្ធ័នេះដំណើរការយ៉ាងដូចម្តេចៈ

យើងរៀបចំស្រះតូចៗចាប់តាំងពីខែ ធ្នូ ហើយទិញកូនត្រីដាក់នៅពេលមានភ្លៀងធ្លាក់ ហើយពិនិត្យមើលគុណភាពទឹកដោយប្រើក្រដាស់ជ្រលក់ពិនិត្យគុណភាព បើសិនជាក្រដាស់ជ្រលក់ឡើងពណ៌ផ្កាឈូក ឬ ក្រហមត្រូវដាក់កំបោរបន្ថែម។ យើងប្រើសាច់មងក្រឡាញ៉ើក និងបំពង់ប្រមូលបួង់តុង ដើម្បីពិនិត្យមើលចំនួនបួង់តុង រៀងរាល់ ៣-៧ ថ្ងៃម្តង ដើម្បីកំណត់បរិមាណជី និងកន្ទក់បន្ថែម។ បន្ទាប់មកត្រូវផ្ទេរទៅស្រះផ្សេងទៀត បើសិនជាដង់ស៊ីតេកូនត្រីច្រើនពេក។ ត្រីកាបស ឬត្រីកាបសាមញ្ញអាចមានទម្ងន់ ២៥០-៣០០ ក្រាម និង ត្រីកាបឥណ្ឌា (Rohu, Catla and Mrigal) មានទម្ងន់ ៥០-១០០ ក្រាម។ បើសិនមានភ្លៀងនៅខែ កញ្ញា-តុលា ហើយទឹកអាចនៅរហូតដល់ខែមករា ត្រីកាបឥណ្ឌាអាចមានទម្ងន់ ២៥០-៣០០ ក្រាម ហើយត្រីកាបស និង កាបសាមញ្ញអាចមានទម្ងន់លើសពី ០,៥ គ.ក។

លោក Nitya បាននិយាយថា "យើងហូបត្រីដោយសារវាមានតម្លៃតែ ៣០ រូពី/គ.ក ប៉ុណ្ណោះ ប៉ុន្តែសាច់មាន់វិញមានតម្លៃរហូតដល់ ១០០ រូពី/គ.ក។ បើសិនយើងចង់ហូបសាច់ពពែ គឺសម្រាប់ហូបច្រើនគ្នា ចំណែកត្រីវិញយើងអាចហូបម្នាក់ ឬពីរនាក់បាន។ យើងលក់របស់ច្រើន កូនត្រីមានតំលៃផ្សេងៗគ្នា បើសិនជាមានកូនត្រីធំនៅដើមរដូវ អាចលក់បានតម្លៃថ្លៃ។ នៅពេលដែលយើងដាក់កូនត្រីច្រើននៅក្នុងស្រះ កូនត្រីមិនសូវធំធាត់។ គេទាំងអស់គ្នាដឹងថាពេលដែលកូនត្រីនេះដាក់នៅស្រះធំទូលាយ វានឹងធំធាត់ឆាប់រហ័ស ដូច្នេះអ្នកមានស្រះធំៗតែងតែមកទិញកូនត្រីពីយើងក្នុងតម្លៃ ៩០-១០០ រូពី/គ.ក។ ត្រីដែលប្រមូលផលបាន លក់នៅនឹងកន្លែងមានតម្លៃ ២០-៣០ រូពី/គ.ក ត្រីធំលក់ក្នុងតម្លៃ ៦០-៧០ រូពី/គ.ក ទៅឱ្យម្ចាស់ស្រះដើម្បីទុកធ្វើមេពូជ។

**ឥទ្ធិពលនៃភាពបត់បែនឥណទានជនបទ**

ក្នុងខែឧសភា ២០០០ ធនាគារកណ្តាលនៃប្រទេសឥណ្ឌាបានចេញសារាចរណែនាំមួយឱ្យធនាគារអភិវឌ្ឍន៍ជនបទ ធ្វើការកែប្រែបែបបទរបស់ខ្លួន ធ្វើយ៉ាងណាឱ្យក្រុមជួយខ្លួនឯងអាចខ្ចីប្រាក់ពីធនាគារបាន ដោយមិនចាំបាច់ដាក់វត្ថុបញ្ចាំ ហើយការសងប្រាក់ត្រូវមានការបត់បែន ដោយឱ្យក្រុមអាចសងប្រាក់ខ្លះ ឬសងទាំងអស់ក្នុងរយៈពេលរហូតដល់ ៣ ឆ្នាំ។ អត្រាការប្រាក់ប្រចាំឆ្នាំគឺ ១២% បើប្រៀបធៀបឈ្មួញចងការប្រាក់ ៥ -១០% ក្នុង១ ខែ។ ធនាគារអាចឱ្យខ្ចីប្រាក់ចាប់ពី ៥០០ រហូតដល់រាប់ពាន់រូពី។

ក្រុមបង្កើតថ្មីអាចជ្រើសតាំងតំណាង ២-៣ នាក់ទៅធនាគារ ដោយមានវិញ្ញាបនបត្រ័បញ្ជាក់ពីការបង្កើតក្រុម និងតារាងលំអិតពីប្រាក់សន្សំរបស់ពួកគេ ផែនការរបស់ពួកគេ(រួមទាំងចំនួនប្រាក់ដែលចង់ខ្ចី) និង ពីគោលបំណងនៃការខ្ចីប្រាក់។ ធនាគារត្រូវការកិច្ចព្រមព្រៀងខ្ចីប្រាក់ដែលត្រូវបំពេញ និង ឯកសារដែលមានឈ្មោះថា "តម្រូវការកិច្ចសន្យា"។ ក្រុមណាដែលបានសងប្រាក់គ្រប់ ១០០% អាចខ្ចីលើកទី២ បាន។ ក្រុមជួយខ្លួនឯងដែលចិញ្ចឹមត្រីបានទទួលជោគជ័យ ហើយមានប្រាក់សន្សំច្រើន

ជាងគេ ហេតុដូច្នេះហើយបានជាធនាគារអាចឱ្យខ្ចីលុយបានច្រើន។ លោក Ajit Banerjee បាននិយាយថា "ជាការផ្លាស់ប្ដូរដ៏ធំមួយ គឺថាឥឡូវនេះក្រុមគិតថា ឥណទានគឺជាធនធានមួយដែលក្រុមបានប្រើប្រាស់ និង ត្រូវសងវិញ។ ក្រុមជួយខ្លួនឯងចំនួន ៤០ នៅក្នុងភូមិ Jabarrah ឥឡូវមានប្រាក់សន្សំសរុបរាប់លានរូពី និង អាចខ្ចីលុយពីធនាគាររាប់លានរូពី។

ទាក់ទងនឹងការផ្លាស់ប្ដូរ ស្ដ្រីម្នាក់បាននិយាយថា " ខែវស្សាគឺជាខែត្រូវបណ្ដាសា ដោយសាយើងគ្មានលុយ ហើយគ្មានអ្វីហូប "។ យើងត្រូវបញ្ចាំវត្ថុផ្សេងៗដើម្បីបានលុយពីអ្នកចងការក្នុងអត្រាការប្រាក់ខ្ពស់។ អ្នកស្រី Lalita Mahato បាននិយាយថា "មានពេលមួយយើងមិនហ៊ាននិយាយរកក្រុមបុរសនៅក្នុងភូមិ កុំគិតពីអ្នកចំលែក! ឥឡូវនេះយើងអាចទៅធនាគារហើយអាចខ្ចីលុយ ទៅសួរនាំអាជ្ញាធរ ហើយលើកឡើងពីការលំបាករបស់យើង ហើយយើងអាចប្រឈមមុខនិងបញ្ហាទាំងឡាយបាន។ យើងមានសេចក្ដីរីករាយដោយសំដីរបស់យើងត្រូវបានគេស្ដាប់ ហើយគោរព។

**គ្រាន់តែជាក្ដីស្រមៃ**

ការជួយដោយអំណត់ធន់ដល់ក្រុមជួយខ្លួនឯង ដោយគម្រោង EIRFP ហើយឥឡូវនេះគឺអ្នករៀបចំសហគមន៏GVT គឺជាឆ្អឹងខ្នងនៃដំណើរការអភិវឌ្ឍន៏នៅភូមិ Jabarrah។ មានការអភិវឌ្ឍន៏បែបនេះគឺដោយសារការរួមផ្សំការស្រាវជ្រាវរកបច្ចេកទេសសមស្របដោយកសិករ ជាមួយនឹងការជួយឧបត្ថម្ភពីគម្រោង DFID, NRSP និង ការផ្លាស់ប្ដូរប្រពន្ធ័មីក្រូឥណទាន ដែលធ្វើឡើងដោយធនាគារកណ្ដាល និង ដោយមានការអនុវត្តន៏ដោយប្រុងប្រយត្ន័ពីធនាគារ Maubhun Gramin។ ការអភិវឌ្ឍន៏នេះបានផ្ដល់ឱកាសយ៉ាងសំខាន់ដល់បុរស និង ស្ដ្រី ទទួលបាននូវការគោរព និង មានឈ្មោះបោះសំលេង អាចរកប្រាក់ចំណូល អាចសន្សំលុយបាន អាចខ្ចីលុយពីធនាគារ ធ្វើអ្វីតាមគំនិតរបស់ខ្លួន និង មានសុវត្ថិភាព ជៀសវាងការដើរស៊ីឈ្នួលក្រៅភូមិ។
២ ឬ ៣ ឆ្នាំមុន រឿងរ៉ាវទាំងនេះគឺគ្រាន់តែជាក្ដីស្រមៃប៉ុណ្ណោះ។

*Satyendra Tripathi, Graham Haylor and William Savage* ធ្វើការជាមួយ *STREAM* យើងអាចទាក់ទងតាមរយៈអ៊ីមែល <ghaylor@loxinfo.co.th>. *Jagdish Gangwar, Virendra Singh, Gautam Dutta and Prabhat Pathak* ធ្វើការជាមួយ *GVT* យើងអាចទាក់ទងតាមរយៈអ៊ីមែល <rch_gvteirfp@sancharnet.in>.

# ការធ្វើអន្តរាគមន៍ដល់ជីវភាពរស់នៅដោយទីភ្នាក់ងារអភិវឌ្ឍន៍កសិករចិញ្ចឹមត្រីៈ ការងារទទួលបានជោគជ័យពីស្រុក Mayurbhanj នៃរដ្ឋ Orissa

*G B Parida*

**ពីភូមិ** Fulwar Toli **ទៅភូមិ** Jabarrah **និង ពេលត្រលប់មកវិញ**

Bhim Nayak នៅភូមិ Fulwar Toli ជាភូមិមួយស្ថិតនៅក្នុងស្រុក Ranchi ក្នុងរដ្ឋ Jharkhand ។ ភូមិមានប្រជាជនប្រហែល ៩០០នាក់ ភាគច្រើនពួកគេគ្មានដីធ្លី ហើយដើររកការងារធ្វើនៅទីក្រុងជិតភូមិ ។ អត្រាចេះអាន និង សរសេរនៅក្នុងភូមិមានកំរិត តែ ២០%ប៉ុណ្ណោះ ។

ក្នុងខែកញ្ញា ២០០៣ លោក Bhim Nayak បានចូលរួមក្នុងដំណើរទស្សនកិច្ចមួយដែលរៀបចំឡើងដោយ NACA-STREAM ទៅពិនិត្យកំរងភូមិ Jabarrah នៅក្នុងរដ្ឋ West Bengal ( សូមអានអត្ថបទពីរខាងដើម) ។ ក្នុងកំឡុងពេលដំណើរ ទស្សនកិច្ច លោក Bhim បានដឹងពីរបៀបចងក្រងក្រុមជួយខ្លួនឯង ហើយក្រុមទាំងនេះបានធ្វើសកម្មភាពជាច្រើន ហើយមានការជួយជ្រោមជ្រែងពីធនាគារ ។



ក្នុងពេលទស្សកិច្ចនៅកំរងភូមិ Jabarrah លោក Bhim Nayak បាននិយាយទាក់ទងនឹងបទពិសោធរបស់គាត់ជាមួយក្រុមស្ត្រីជួយខ្លួនឯងនៅភូមិ Fulwar Toli

បន្ទាប់ពីបានទស្សនកិច្ចហើយ លោក Bhimបានសំរេចជំរុញបង្កើតឱ្យមានក្រុមជួយខ្លួនឯងនៅក្នុងភូមិរបស់គាត់ ។ គាត់បានប្រមូលមិត្តភក្តិ និង អ្នកជិតខាងទាំងអស់ និង ពន្យល់ពីផលប្រយោជន៍នៃការចងក្រងជាក្រុមជួយខ្លួនឯង ។ ពួកគេក៏យល់ព្រមជាមួយគំនិតរបស់គាត់ ហើយបានបង្កើតក្រុមជួយខ្លួនឯងចំនួន ៤ ក្រុម ដោយក្រុមនិមួយៗមានគោលបំណងជាក់លាក់ ។

**ក្រុម បទដ្ឋាន និង សកម្មភាព**

ក្រុមទី១

ក្រុម Ambedkar Carrier Library គឺដើម្បីលើកកំពស់ចំណេះដឹង និង ការអប់រំ ។ តួនាទីរបស់ក្រុមគឺ ប្រមូល និង ទិញសៀវភៅសំរាប់ប្រឡង និង អប់រំដល់មនុស្សដ៏ទៃទៀតដោយរួមទាំង កូនក្មេង និង ក្មេងជំទង់ ។ មានតែអ្នកមានចំណេះដឹងទេទើបអាចក្លាយជាសមាជិកបាន ហើយពួកគេពាក់ពន្ធ័នឹងសកម្មភាពបង្រៀន ។ ក្រុមនេះមានសមាជិក ២៥ នាក់ ក្នុងនោះមានស្ត្រី ៦ នាក់ ។ សមាជិកម្នាក់ៗត្រូវបង់លុយ ៥ រូពីរៀងរាល់អាទិត្យក្នុងមូលនិធិរបស់ក្រុម ដែលលុយទាំងនេះត្រូវបានគេប្រើដើម្បីទិញសៀវភៅ ។ ទាំងនេះគឺជាអ្នកសំរបសំរួលសង្គម ហើយពួកគេក៏បានណែនាំពីសកម្មភាពកសិកម្ម និង ជលផល ។

ក្រុមទីពីរ

នេះគឺជាក្រុមស្ត្រីដែលមិនទាន់មានឈ្មោះនៅឡើយ ។ ក្រុមនេះមានសមាជិក១២ នាក់ដែលសុទ្ធសឹងជាប្រពន្ធរបស់អ្នកនេសាទ ហើយពួកគេគឺជាអ្នកលក់ត្រី ។ ពួកគេត្រូវបង់លុយ ១០ រូពីរៀងរាល់អាទិត្យក្នុងមូលនិធិរបស់ក្រុម ។ ពួកគេមានផែនការ

ដាក់លុយនេះនៅក្នុងធនាគារ ដូច្នេះនៅពេលមានគ្រោះអាសន្ន  ពួកគេអាចប្រើប្រាស់លុយនេះ ជៀសវាងខ្ចីលុយពីឈ្មួញដែលយកការប្រាក់ខ្ពស់

ក្រុមទីបី

ក្រុម Devi Mansa  មានសមាជិកចំនួន១១រូប ដែលពាក់ពន្ធ័នឹងការងារកសិកម្ម។ ពួកគេត្រូវបង់លុយ ៥ រូពីរៀងរាល់អាទិត្យក្នុងមូលនិធិរបស់ក្រុម។ ពួកគេទិញស្រូវ ហើយកិន យកទៅលក់នៅផ្សារ។ ពួកគេក៏ទិញបន្លែពីអ្នកលក់ដុំ ហើយយកមកលក់នៅទីផ្សារក្នុងតំបន់ និង ភូមិ។

ក្រុមទីបួន

ក្រុមជួយខ្លួនឯងអ្នកនេសាទ មានសមាជិកបុរសចំនួន ២៨ នាក់ ពាក់ពន្ធ័នឹងការចិញ្ចឹមត្រី។ ពួកគេគ្រប់គ្រង និងថែរក្សាដែននេសាទរដ្ឋ និង ឯកជន។ ពួកគេត្រូវបង់លុយ ៥ រូពីរៀងរាល់អាទិត្យក្នុងមូលនិធីរបស់ក្រុម។ ពួកគេជួបជុំគ្នារៀងរាល់អាទិត្យពិភាក្សាគ្នាពីបច្ចេកទេសចិញ្ចឹមត្រីថ្មីៗ និង ពីបញ្ហាផ្សេងៗដូចជា ថែរក្សាដែននេសាទដែលមានស្រាប់ ប្រាក់ចំណេញ និង វិធីសាស្ត្របញ្ឈប់ការញៀនស្រា។

**ផលប្រយោជន៏នៃក្រុមជួយខ្លួនឯង**

បន្ទាប់ពីចងក្រងក្រុមជួយខ្លួនឯងហើយ អ្នកភូមិ FUlwar Toli បានដឹងពីផលប្រយោជន៏រួចទៅហើយៈ

- សមាជិកក្រុមឥឡូវនេះបានដឹងពីសារៈសំខាន់នៃការសន្សំ
- អ្នកភូមិមានការជឿជាក់កាន់តែខ្លាំង លើសកម្មភាពផ្សេងៗ ដើម្បីលើកកំពស់ស្ថានភាពភូមិ
- ឥឡូវនេះពួកគេអាចដឹងពីវិធីលើកកំពស់ជីវភាពរស់នៅរបស់គេ
- ពួកគេបានសំរេចកសាងសាលារៀនតូចមួយនៅក្នុងភូមិ ដោយប្រើប្រាស់ថវិការបស់ក្រុម
- ឥឡូវនេះអ្នកភូមិទាំងអស់បានពាក់ពន្ធ័នឹងសកម្មភាពទាំងនេះ
- ឥឡូវភូមិបានទទួលការគាំទ្រពី *NGO* ហើយបន្ទាប់ពីសន្សំបាន រយៈពេល ៦ខែ ក្រុមអាចមានសិទ្ធិខ្ចីលុយពីធនាគារជនបទបាន។



ក្រុមភ្លេងភូមិ Fulwar Toli លេងក្នុងពិធីមង្គលការ និង ពិធីផ្សេងៗទៀត ដើម្បីរកប្រាក់ចំណូល

លោក *Bhim Nayak* គឺជាប្រធានភូមិ *Fulwar Toli Village* ក្នុងស្រុក *Ranchi* រដ្ឋ *Jharkhand*។ លោក *Rubu Mukherjee* គឺជាអ្នកគ្រប់គ្រងមណ្ឌលទំនាក់ទំនងរបស់ *STREAM* នៅប្រទេស *India*ដែលមានមូលដ្ឋាននៅស្រុក *Ranchi*។ យើងអាចទាក់ទងពួកគេតាមរយៈអ៊ីមែល <streamindia@sancharnet.in>.

## ការធ្វើអន្តរាគមន៍ដល់ជីវភាពរស់នៅដោយទីភ្នាក់ងារអភិវឌ្ឍន៍កសិករចិញ្ចឹមត្រី: ការងារទទួលបានជោគជ័យពីស្រុក Mayurbhanjនៃរដ្ឋ Orissa

*G B Parida*

### រឿងរបស់ទីភ្នាក់ងារអភិវឌ្ឍន៍កសិករចិញ្ចឹមត្រី (FFDA) និង កសិករម្នាក់

FFDA មានទីតាំងស្ថិតនៅស្រុក Mayurbhanj រដ្ឋ Orissa ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៧៨ ដោយមានគោលបំណងបង្កើនការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ និង ឧស្សាហកម្ម។ នេះគឺជារឿងសហគ្រាសចិញ្ចឹមត្រីទទួលបានជោគជ័យដែលបង្កើតឡើងដោយកសិករចិញ្ចឹមត្រី។

លោក Shri Pulin Kumar Behera រស់នៅភូមិ Nuegaon ក្នុងស្រុក Mayurbhanjបានចាប់ផ្ដើមចិញ្ចឹមត្រីតាមរយៈការជួយឧបត្ថម្ភពីគំរោង FFDAក្នុងឆ្នាំ ១៩៨០។ គាត់ចាប់ផ្ដើមចិញ្ចឹមត្រីនៅក្នុងស្រះដែលមានទំហំ ០,២៤ ហ.ត ដោយគាត់បានខ្ចីលុយពីធនាគារចំនួន ៦ ពាន់រូពី។ ដោយទទួលបានជោគជ័យក្នុងការចិញ្ចឹមត្រី លោក Shri ចង់ពង្រីកសកម្មភាពចិញ្ចឹមត្រីរបស់គាត់។ អង្គការ FFDAក៏បានជួយគាត់ម្ដងទៀត។

### ស្រះ ប្រាក់កម្ចី និង ការឧបត្ថម្ភធនការ

ក្នុងឆ្នាំ ១៩៨៥ គាត់បានពង្រីកការចិញ្ចឹមត្រីនៅលើផ្ទៃស្រះ ០,៥៤ ហ.ត ដោយប្រាក់កម្ចីពីធនាគារចំនួន ២៥.០០០រូពី ក្នុងនោះរដ្ឋាភិបាលបានឧបត្ថម្ភជាប្រាក់ចំនួន ១,៣៥០ រូពី។ ដោយចាប់អារម្មណ៍ខ្លាំងនឹងការចិញ្ចឹមត្រី រួមផ្សំនឹងការលើកទឹកចិត្តពីអង្គការ FFDA លោក Shri បានពង្រីកស្រះមួយទៀតទំហំ ០,៥ ហ.ត ក្នុងឆ្នាំ ១៩៩២-៩៣ ដោយប្រាក់កម្ចីពីធនាគារចំនួន ៥០.០០០ រូពី ក្នុងនោះអង្គការបានឧបត្ថម្ភគាត់ចំនួន ១០.០០០រូពី។ លោក Shri បានពង្រីកកសិដ្ឋានរបស់គាត់បន្ថែមទៀតក្នុងឆ្នាំ ២០០១-០២ ដោយជីកស្រះបន្ថែមទំហំ ១.៤ ហ.ត ដោយខ្ចីប្រាក់ពីធនាគារចំនួន ៣៨៥.០០០ រូពី ក្នុងនោះប្រាក់ឧបត្ថម្ភពីរដ្ឋាភិបាល មានចំនួន ៧៩.០០០ រូពី។ ដូចគ្នានោះដែរ គាត់ក៏បានពង្រីកស្រះ ១ ទៀតមានទំហំ ០,៣ ហ.ត ដោយខ្ចីប្រាក់ពីធនាគារចំនួន ៨០.០០០ រូពី ហើយជំនួយពីអង្គការ ១៨,៤០០ រូពី។

### ត្រី កូនត្រី មាន់ទា និង បន្លែ

មុនពេលបង្កើតអង្គការ FFDA លោក Shri ធ្វើតែស្រែចំការទេ។ ប៉ុន្តែដោយគាត់មានចំណាប់អារម្មណ៍ និង មានការជួយឧបត្ថម្ភពីអង្គការ មកទល់ថ្ងៃនេះលោក Shri គឺជាកសិករគំរូម្នាក់នៅក្នុងស្រុកដែលមានផ្ទៃដីកសិកដ្ឋាន ១,៧៤ ហ.ត។ គាត់មិនត្រឹម តែចិញ្ចឹមត្រីទេ ប៉ុន្តែគាត់ថែមទាំងផលិតកូនត្រីទៀតផង។ ក្នុងឆ្នាំ ២០០៣-០៤ គាត់បានផលិត និងលក់កូនត្រីបានចំនួន ២ លាន ក្បាលទៅឱ្យកសិករឯទៀតៗនៅក្នុងស្រុក ហើយអាចរកប្រាក់ចំណូល ៤០.០០០ រូពី។ គាត់អាចចិញ្ចឹមត្រីទទួលបានទិន្នផល រហូតដល់ ៣តោន/ហិចតា។ លោក Shri បាននិយាយថា គាត់អាចរកប្រាក់ចំណូល ២៥០.០០០រូពី/ឆ្នាំ ពីការលក់កូនត្រី និង ត្រីសាច់។ ឥឡូវនេះ គាត់ចាប់ផ្ដើមចិញ្ចឹមត្រីចំរុះជាមួយមាន់ចំនួន ១០០ ក្បាល។ គាត់ក៏ដាំបន្លែនៅតាមមាត់ស្រះ ដូចជា ចេក ម្ទេស ប៉េងប៉ោះ។

**ស្រះ និង ទឹកអណ្តូង**

លោក Shri បានប្រើប្រាស់ទឹកស្រះដើម្បីស្រោចស្រពបន្លែបង្កា និង ធានាការផ្គត់ផ្គង់ទឹកទៀងទាត់ និង ទាន់ពេលវេលា។ គាត់មានអណ្តូងខួងមួយដែលអាចផ្គត់ផ្គង់ទឹកបានគ្រប់ពេល ដោយមិនបាច់ប្រើម៉ាស៊ីនបូមទឹក ។នេះគឺជាអំណោយពីធម្មជាតិសំរាប់គាត់ ដែលធ្វើឱ្យគាត់អាចពង្រីកសកម្មភាពរបស់គាត់បាន។ គាត់ក៏បានជីកអណ្តូងខួងមួយទៀត ហើយបំពាក់ម៉ូទ័របូមទឹកកំលាំង ៥ សេះ ដើម្បីការពារការខ្វះខាតទឹក។

**កសិករម្នាក់ និង អង្គការ** FFDA

ឆ្នាំនេះលោក Shri បានស្តុកកូនបង្កងជាមួយនិង កូនត្រីប្រភេទផ្សេងៗ ដើម្បីរកប្រាក់ចំណូលបន្ថែម។ គាត់ចង់លើកកំពស់សកម្មភាពរបស់គាត់ និង ចង់បង្កើតកន្លែងភ្ញាស់កូនត្រីដោយខ្លួនឯងនៅពេលខាងមុខ។ ហើយចាប់ពីឆ្នាំនេះទៅអង្គការនឹងចាប់ផ្តើមធ្វើការជាមួយក្រុមជួយខ្លួនឯង។

**បទពិសោធដែលទទួលបាន**

ជាការគួរឱ្យកត់សំគាល់ នៅខែមិនា ២០០៣ អ្នកចិញ្ចឹមត្រីមកពីរដ្ឋ Jharkhand បានទស្សនកិច្ចនៅកសិដ្ឋានរបស់លោក Shri។ ពួកគេបានរៀនពីជោគជ័យរបស់គាត់ ហើយបានបញ្ចេញនូវទស្សនៈ លើភាពខ្លាំងរបស់គាត់ដូចតទៅ:

- គាត់មានចំណាប់អារម្មណ៍លើសកម្មភាពចិញ្ចឹមត្រី
- មានឥណទានផ្តល់ឱ្យគ្រប់គ្រាន់
- សងប្រាក់ឱ្យធនាគារទាន់ពេលវេលា ជាហេតុធ្វើឱ្យធនាគារអាចឱ្យគាត់ខ្ចីបន្ត
- គាត់បានប្រើប្រាស់ប្រាក់កម្ចីបានត្រឹមត្រូវ និង មានការឧបត្ថម្ភថវិកា និង អន្តរាគមន៍ពីអង្គការ FFDA

ឆ្នាំនេះអង្គការបានដឹកនាំកសិករចំនួន ១៥ នាក់មកទស្សនកិច្ចនៅកសិដ្ឋានរបស់លោក Shri។ កសិករទាំងអស់មានក្តីរំភើបដោយបានឃើញកសិដ្ឋានរបស់គាត់មានដូចជា ប្រពន្ធ័គ្រប់គ្រងទឹកស្អុយ និង ការចិញ្ចឹមចំរុះត្រី និង បង្កង។



លោក G.B Parida (រូបទីពីរពីឆ្វេងដៃ) និង សហការីមកពីនាយកដ្ឋានជលផល ពិភាក្សាក្នុងសិក្ខាសាលាយុទ្ធសាស្រ្តទំនាក់ទំនងរបស់គម្រោង STREAM ក្នុងរដ្ឋ Orissa ក្នុងខែវិច្ឆិកា ២០០៣

កំណត់ចំណាំពីអ្នកគ្រប់គ្រងមណ្ឌលទំនាក់ទំនងរបស់ STREAM នៅប្រទេសឥណ្ឌា: អង្គការ FFDA ធ្វើការយ៉ាងជិតស្និទជាមួយ STREAM លើការចែករំលែកបទពិសោធ។ ការពិភាក្សាគ្នាតាមរយៈទូរសព្ទ័បានធ្វើជារឿយៗរវាងនាយកអង្គការ FFDA និង STREAM ឥណ្ឌាលើគម្រោងរបស់រដ្ឋាភិបាលជួយដល់អ្នកចិញ្ចឹមត្រី។ សមាជិកនៃអង្គការ FFDA ក៏បានចែករំលែកបទពិសោធរបស់ខ្លួននៅក្នុងសិក្ខាសាលានេះផងដែរ។

លោក *G B Parida* គឺជាមន្ត្រីជលផលស្រុក និង ជានាយកនៃអង្គការអភិវឌ្ឍន៍កសិករចិញ្ចឹមត្រី ។ លោក *Rubu Mukherjee* គឺជាអ្នកគ្រប់គ្រងមណ្ឌលទំនាក់ទំនងរបស់ *STREAM* នៅប្រទេស *India*ដែលមានមូលដ្ឋាននៅស្រុក *Ranchi* ។ យើងអាចទាក់ទងពួកគេតាមរយៈអ៊ីមែល <streamindia@sancharnet.in>.

# ស្វែងយល់ពីធនធាននៃការចិញ្ចឹមជីវិតតាមរយៈការវាយតំលៃជនបទដោយឆាប់រហ័ស (PRA) ដើម្បីលុបបំបាត់ភាពអត់ឃ្លាន

*Binay Sahay*

## ភាពក្រីក្រនៅប្រទេសឥណ្ឌា

ឥណ្ឌាគឺជាប្រទេសធំមួយដែលភាពក្រីក្រនៅតែជាឧបសគ្គចំបង។ មុនពាក់កណ្តាលទសវត្ស ៧០ អត្រាស្ថិតនៅក្រោមបន្ទាត់ភាពក្រីក្រគឺនៅថេរ ៥៥ % និង ពីឆ្នាំ ១៩៧៥-៨៧ មានការថយចុះមកត្រឹម ៣៨%។ វាស្របពេលនឹងអត្រាកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ ៤-៥% (World Bank India, 1997)។ ការកាត់បន្ថយភាពក្រីក្របន្តរហូតដល់ដល់ទសវត្ស ៩០ ប៉ុន្តែសមាមាត្រនៃប្រជាជនដែលរស់នៅក្នុងភាពក្រីក្រថយចុះយឺតៗ ជាពិសេសនៅតំបន់ជនបទ។ ភាពក្រីក្រខុសគ្នាក្នុងចំណោមស្ត្រី ជនជាតិ និងស្រទាប់វណ្ណៈ និង ផ្នែកខ្លះនៃសហគមន៍នៅតំបន់ជនបទ។ យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ និង ភាពអត់ឃ្លាន មានរយៈពេលជាង ៥០ឆ្នាំមកហើយ ដើម្បីធ្វើការស្វែងយល់ឱ្យកាន់តែស៊ីជំរៅពីភាពស្មុគស្មាញរបស់វា។

## បរិវត្តនៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ និង ភាពអត់ឃ្លាន

នៅប្រទេសឥណ្ឌាក្នុងទសវត្ស ៥០ និង ៦០ ភាគច្រើនគេមានទស្សនៈថា ការវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធគឺជាមធ្យោបាយដ៏សំខាន់សំរាប់ការអភិវឌ្ឍន៍។ ក្នុងទសវត្ស ៧០ គេបានដឹងថា ការអភិវឌ្ឍន៍វិស័យហេដ្ឋារចនាសម្ព័ន្ធគឺមិនទាន់គ្រប់គ្រាន់នៅឡើយទេ ចាំបាច់ត្រូវមានវិស័យសុខាភិបាល និង អប់រំផងដែរ។ ក្នុងទសវត្ស ៨០ គេបានរកឃើញយុទ្ធសាស្ត្រពីរផ្នែកនៃការកាត់បន្ថយភាពក្រីក្រគឺ លើកកំពស់ការងារប្រើកំលាំងពលកម្មច្រើន តាមរយៈការបើកចំហរសេដ្ឋកិច្ច និង វិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធ និង ផ្តល់នូវសេវាអប់រំ និង សុខាភិបាលដល់ប្រជាជនក្រីក្រ។ ក្នុងទសវត្ស ៩០ "អភិបាលកិច្ច" និង "ស្ថាប័នបានផ្តោតលើយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រតាមរយៈការលើកកំពស់ឱកាស សំរបសំរួលការផ្ទេរអំណាច លើកកំពស់សុវត្ថិភាព និង កសាងស្ថាប័ន (World Bank,2001)។ ការកាត់បន្ថយភាពក្រីក្របានធ្វើដោយជោគជ័យក្នុង២ ទសវត្សមុន។ គេបានចំណាយថវិកាយ៉ាងច្រើនលើការដោះស្រាយបញ្ហាភាពក្រីក្រ និង លុបបំបាត់ភាពអត់ឃ្លាន ជាពិសេសលើការរួមបញ្ចូលប្រជាជនក្រីក្រនៅក្នុងដំណើរការអភិវឌ្ឍន៍។

## ស្វែងយលពីភាពអត់ឃ្លាន ភាពក្រីក្រ និង ការចិញ្ចឹមជីវិត

ភាពក្រីក្រគឺមានទំនាក់ទំនងយ៉ាងជិតស្និទនិងកង្វះខាតធនធាន ឬក៏មិនអាចប្រើប្រាស់ធនធានឱ្យមានប្រសិទ្ធិភាព។ គ្រោះអត់ឃ្លានគឺជារោគសញ្ញានៃភាពក្រីក្រខ្លាំង មូលហេតុរបស់វាគឺ ការមិនរាប់បញ្ចូលទៅដំណើរវិវត្តន៍ក្នុងសង្គម សេដ្ឋកិច្ច និង ការអប់រំ គ្មានអំណាច ខ្វះតំណាង ឬសំលេង ឈឺច្រើន ហើយមានចំណូលមិនគ្រប់គ្រាន់។

"ភាពអត់ឃ្លាន "មានន័យប្រហាក់ប្រហែលនឹងពាក្យ "គ្មានសុវត្ថិភាពស្បៀង " ដោយប្រជាជនក្រីក្រគ្មានមធ្យោបាយផលិតកម្មដើម្បីទទួលបានស្បៀងអាហារហូបគ្រប់គ្រាន់តាមរយៈការដាំដុះ និង ទិញ។

គម្រោង FFDA យល់ថាការចិញ្ចឹមជីវិតរបស់មនុស្សម្នាក់ៗ ឬសហគមន៍ គឺផ្អែកលើធនធានដែលត្រូវបានគេចាត់ថ្នាក់

ដូចជា ធនធានមនុស្ស ធនធានសង្គម ធនធានធម្មជាតិ ធនធានហេដ្ឋារចនាសម្ព័ន និង ធនធានហិរញ្ញវត្ថុ (Carney, 1998)។ ដើម្បីកសាងយុទ្ធសាស្ត្រលុបបំបាត់ភាពអត់ឃ្លាន យើងត្រូវដឹងពីការប្រើប្រាស់ធនធាន និង សារៈសំខាន់របស់វានៅក្នុងជីវិតរបស់ប្រជាជន ដូច្នេះយើងអាចលើកកំពស់ការចិញ្ចឹមជីវិតរបស់ពួកគេបាន។



សមាជិកសហគមន៍ធ្វើផែនទីសង្គម

**ប្រើប្រាស់ PRA ដើម្បីស្វែងយល់ពីការចិញ្ចឹមជីវិត**

គម្រោង EIRFP មានបទពិសោធក្នុងការប្រើប្រាស់ PRA ដើម្បីស្វែងយល់ពីវិធីដែលប្រជាជន និង សហគមន៍ប្រើប្រាស់ធនធានដើម្បីធ្វើការចិញ្ចឹមជីវិត។ ទិសដៅសំខាន់មួយគឺលើកកំពស់សុវត្ថិភាពស្បៀង។ វិធីសាស្ត្រ PRA បានសំរបសំរួលសហគមន៍ស្ថិតក្រោមគម្រោងពិនិត្យមើលខ្លួនឯងពី ស្ថានភាព និង លទ្ធភាពរបស់ពួកគេ ហើយអាចឱ្យពួកគេប្រើប្រាស់នូវលទ្ធផលឱ្យមានប្រយោជន៍ និង យកទៅអនុវត្តបាន។ តាមរយៈការរកនូវបញ្ហា ធ្វើឱ្យពួកគេមានការវិភាគ និង យល់ដឹងកាន់តែស៊ីជំរៅ។

យុទ្ធសាស្ត្រចូលរួមត្រូវបានប្រើប្រាស់ដោយគម្រោងៈ ស្វែងយល់ពីឫសគល់នៃភាពអត់ឃ្លាន ដោយរួមបញ្ចូលទាំងការស្វែងយល់ពីធនធានការចិញ្ចឹមជីវិត ដំណើការ ស្ថាប័ន និង ការអនុវត្តន៍ ដែលមានឥទ្ធិពលលើវិធីដែលប្រជាជនក្រីក្រប្រើប្រាស់វា។ វិធាន PRA មិនគ្រាន់តែប្រមូលពតិមានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើនការយល់ដឹងរបស់អ្នកដែលពាក់ពន្ធ័នឹងការប្រយុទ្ធប្រឆាំងភាពក្រីក្រ និង អត់ឃ្លាន ពីរបៀបប្រើប្រាស់ធនធានដើម្បីលើកកំពស់ការចិញ្ចឹមជីវិតរបស់ពួកគេ។ ខាងក្រោមជាឧទាហរណ៏ពីវិធានដែលគម្រោងបានប្រើប្រាស់ៈ

| **ធនធានមនុស្ស** | **ធនធានសង្គម** | **ធនធានធម្មជាតិ** |
|---|---|---|
| ពតិមានទូទៅ<br>ជំនាញ និង មុខរបរ<br>តួនាទី និង ការទទួលខុសត្រូវរបស់ Gender<br>សុខភាព និង ជីវជាតិ | ផែនទីសង្គម<br>ចំណាត់ថ្នាក់ទ្រព្យសម្បត្តិ<br>មែកធាងគ្រួសារ<br>និន្នាការបំលាស់ទី | ផែនទីធនធានធម្មជាតិ<br>ពំនុះកាត់ទទឹង<br>ប្រតិទិនរដូវកាល<br>ចំណាត់ថ្នាក់តាមតារាងម៉ាទ្រិច<br>និន្នាការព្រៃឈើ និង សត្វពាហនៈ |

| **ធនធានរូបវន្ត** | **ធនធានហិរញ្ញវត្ថុ** |
|---|---|
| ផែនទីភូមិសាស្ត្រ<br>ផែនទីស្ថាប័ន និង ហេដ្ឋារចនាសម្ព័ន | ស្ថាប័នសន្សំ<br>ស្ថាប័នឥណទាន |

## ឯកសារយោង

Carney D 1998 *Sustainable Rural Livelihood: What Contribution Can We Make?* London, UK: Department for International Development.

Tomar V S, Gangwar J S and Sahay B K 2001 *Evolution of Sustainable Livelihoods Strategy for Poor Men and Women: An Experience of EIRFP*. Copenhagen, Denmark: www.anthrobase.org

World Bank 2001 *Attacking Poverty – Opportunity, Empowerment and Security: A World Development Report 2000-01*. Washington, DC, USA: World Bank.

World Bank India 1997 *Achievement and Challenge in Reducing Poverty*. Delhi: World Bank India.

លោក *Binay Sahay* គឺជាអ្នកជំនាញខាងអភិវឌ្ឍន៍សង្គមធ្វើការឱ្យ *GVT* មានមូលដ្ឋាននៅស្រុក *Ranchi* រដ្ឋ *Jharkhand* យើងអាចទាក់ទងគាត់តាមរយៈអ៊ីមែល < sahaybinay@yahoo.com >.

# វិធានចាត់ថ្នាក់ភាពក្រីក្រក្នុង PRA :បទពិសោធពីគម្រោង EIRFPក្នុងការលើកឡើងពីបញ្ហាភាពងាយរងគ្រោះ

*Binay Sahay*

**ចំណាត់ថ្នាក់ភាពក្រីក្រក្នុងគម្រោង** EIRFP

ដោយប្រើវិធានចំណាត់ថ្នាក់ភាពក្រីក្រ គម្រោងបានសំរបសំរួលអ្នកភូមិ ចាត់ថ្នាក់សមាជិកសហគមន៍ជា ៣ ប្រភេទ ដោយកំណត់លក្ខណៈវិនិច្ឆ័យដោយខ្លួនឯង:

១. អ្នកសល់: មានដី មានមុខជំនួញ ឬផ្តល់សេវាកម្ម មានលទ្ធភាពទិញ មានសម្ភារៈផលិតកម្ម មានលុយសម្រាប់ឱ្យខ្ចី មានលទ្ធភាពទិញម្ហូបអាហារ និង សំលៀកបំពាក់បានពេញមួយឆ្នាំ

២. អ្នកមួយគ្រប់: មានដីនៅតំបន់ទួល ជួលដីគេចែកផល គ្មានឬមានស៊ីឈ្នួលគេខ្លះ អាចផ្គត់ផ្គង់អាហារពីរពេល/ថ្ងៃ គ្មាន ឬ មានរកការងារធ្វើក្រៅសហគមន៍តិចតួច

៣. អ្នកខ្វះ: មានដីតិចតួច ឬគ្មានដី ដីគ្មានជីវជាតិ ជួលដីគេចែកផល ឬចិញ្ចឹមសត្វប្រវ៉ាស់ ស៊ីឈ្នួលគេ ពេលខ្លះដាច់ពេល ដើររកការងារធ្វើក្រៅសហគមន៍ ផ្ទះទ្រុឌទ្រោម ជំពាក់បំណុលគេ។

ប្រភេទអ្នកខ្វះត្រូវបានគេស្គាល់ថាជា "អ្នកក្រីក្រជាងគេ ក្នុងចំណោមអ្នកក្រ " ។ គម្រោងបានកំណត់បន្ថែមទៀតលើប្រភេទអ្នកខ្វះដូចតទៅ:

- ខ្វះខាតល្មម: មានដីតិចតួច ហើយភាគច្រើនមានដីនៅតំបន់ខ្ពស់ ឬ គ្មានដី ពឹងផ្អែកលើការលក់កំលាំងពលកម្មប្រចាំថ្ងៃដើម្បីចិញ្ចឹមជីវិត ឬ ស៊ីឈ្នួលទូលរបស់របរគេ ក្នុងគ្រួសារមានកំលាំងពលកម្មតិច និង គ្រួសារដែលមានកូនតូចៗ ដើររកការងារធ្វើក្រៅរាប់ខែ ក្រុមដែលមានជំនាញតាមបែបបុរាណ និង អ្នកដែលមានវណ្ណៈទាបនៅក្នុងភូមិ
- ស្ទើររស់ ស្ទើរស្លាប់: មនុស្សចាស់ជរា ពិការ ឬមានជំងឺសរសៃរប្រសាទ និង គ្មានគ្រួសារជួយទំនុកបំរុង គ្មានផ្ទះសំបែង គ្រួសារដែលខ្វះទឹក ស្ត្រីមេម៉ាយដែលមានកូនតូចៗហើយគ្មានគ្រួសារជួយទំនុកបំរុង សមាជិកគ្រួសាររស់នៅដោយមានជំងឺជាប់ខ្លួន ហើយពេលខ្លះដើរសុំទានគេ។

ក្នុងការធ្វើលំហាត់ចំណាត់ថ្នាក់ភាពក្រីក្រ អ្នកភូមិបានចាត់ថ្នាក់ ៥ ប្រភេទ។ ចំណាត់ថ្នាក់ទី៥ គឺគ្រួសារទុរគត ដែលការចាត់ថ្នាក់នេះប្រហាក់ប្រហែលនឹងការចំណាត់ថ្នាក់របស់គម្រោងដែរ។

គ្រួសារអត់ល្មម នៅក្នុងចំណាត់ថ្នាក់ទី៤គឺគ្រួសារដែលខិតខំរកម្ហូបអាហារពេញមួយឆ្នាំ ហើយជួបបញ្ហាខ្វះជីវជាតិ។ កូនចៅរបស់ពួកគេមិនបានទៅរៀន ដោយសាក្រុមគ្រួសារត្រូវដើររកការងារធ្វើខាងក្រៅ

ចំណាត់ថ្នាក់ទី៣ គ្រួសារខ្វះខាតតិចតួច គឺគ្រួសារដែលមានកំលាំងពលកម្មច្រើន។ភាពខុសគ្នារវាងចំណាត់ថ្នាក់ទី ៣ និង ៤ គឺគ្រួសារចំណាត់ថ្នាក់ទី៣ មានសុវត្ថិភាពស្បៀងគ្រាន់បើជាង។ ភាគច្រើនគ្រួសារចំណាត់ថ្នាក់ទី៣ រកស៊ីលក់ដូរសត្វចិញ្ចឹមលេង និង លក់ដូរតិចតួចនៅតំបន់ទីប្រជុំជនក្បែរៗភូមិ។ ភាគច្រើនពួកគេមានចំណីអាហារហូបចុកពេញមួយឆ្នាំ។

ចំណាត់ថ្នាក់ទី១ និង ២ គឺមានភាពងាយរងគ្រោះតិចតួច ទោះបីក្រុមនេះមិនមែនជាក្រុមទិសដៅរបស់គម្រោងក៏ដោយ ការចូលរួមរបស់ពួកគេមានសារៈសំខាន់ណាស់ ដោយសារធនធាន និង ជំនាញរបស់ពួកគេអាចយកមកប្រើប្រាស់ ដើម្បីជាប្រយោជន៍ដល់ស្ត្រី និង បុរសក្រីក្រ។

**យុទ្ធសាស្ត្រ**

ទំរង់នៃការចិញ្ចឹមជីវិតរបស់ក្រុមផ្សេងៗ ដែលកំណត់ដោយគម្រោងតាមរយៈវិធានចំណាត់ថ្នាក់ភាពក្រីក្រ បានបង្ហាញថា ក្រុមនិមួយៗមានយុទ្ធសាស្ត្រដោះស្រាយបញ្ហាខ្វះខាតខុសៗគ្នា។ គ្រួសារខ្វះខាតល្មមដើររកការងារធ្វើក្រៅរយៈពេលយូរ ឬក៏ធ្វើការងារដែលមានប្រាក់ចំណូលទាប ដូចជាទូលរបស់របរគេ ឬ ដើររកអុសលក់។ គ្រួសារទុរគតតែងតែរស់នៅក្នុងស្ថានភាពខ្វះជីវជាតិ និង ទុក្ខសោកជាប្រចាំ។ គ្រួសារទាំងនេះមិនអាចខ្ចីលុយគេដើម្បីទិញម្ហូបអាហារបានទេ។

យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់គម្រោងបានអភិវឌ្ឍន៍យុទ្ធសាស្ត្រផ្សេងៗ ដោយផ្អែកលើស្ថានភាពគ្រួសារ ហើយសំរបសំរួលសហគមន៍ឱ្យជួយដោះស្រាយបញ្ហាភាពក្រីក្រទាំងផ្នែកសេដ្ឋកិច្ច និង សង្គម។ យុទ្ធសាស្ត្ររបស់គម្រោងរួមមានការបង្កើតបរិយាកាសដើម្បីឱ្យមានការផ្លាស់ប្តូរ។ បង្កើនការយល់ដឹងក្នុងចំណោមសមាជិកសហគមន៍ និង លើកទឹកចិត្តឱ្យមានការចូលរួមរបស់ជនជាតិភាគតិច និង ស្ត្រី។ គម្រោងបានឱ្យអ្នកមានរៀបចំសហគមន៍ដែលមានជំនាញវិទ្យាសាស្ត្រសង្គម ផ្តួចផ្តើមដំណើរការអភិវឌ្ឍន៍ដោយមានការចូលរួម និង សរសេររបាយការណ៍ពីក្រុមគោលដៅ។ សកម្មភាពទាំងនេះរួមមានការចុះសាកសួរដោយផ្ទាល់ ប្រជុំ ហើយពេលខ្លះមានចែកចាយគ្រាប់ពូជ។

យុទ្ធសាស្ត្រផ្តោតទៅលើក្រុមបាននូវការទទួលស្គាល់ពីសង្គម ស្ថានភាព និង សុវត្ថិភាពសង្គម ជាពិសេសសំរាប់អ្នកក្រីក្រជាងគេ ហើយជួយពួកគេឱ្យចូលរួមនៅក្នុងដំណើរការសំរេចចិត្ត។ វាក៏បានលើកទឹកចិត្តគ្រួសារក្រីក្រឱ្យមានក្រុមជួយខ្លួនឯងដែលបង្កលទ្ធភាពឱ្យពួកគេអាចខ្ចីលុយពីធនាគារសំរាប់ធ្វើអ្វីម្យ៉ាង។ ការលើកកំពស់ធនធានមនុស្ស និង សង្គមបានបង្កើតឱ្យមានឱកាសសំរាប់សមាជិក ក្រុម និង សហគមន៍។

**ករណីគ្រួសារទុរគតមួយ**

ជំនួយបន្តិចបន្តួចអាចឱ្យគ្រួសារមួយពុះពារបញ្ហាបាន- គ្មានអ្នកណាដឹងរឿងនេះជាងអ្នកស្រី Ravati Mahato រស់នៅក្នុងស្រុក Kaipara នៃរដ្ឋ West Bengal ទេ។ ជាស្ត្រីមេម៉ាយដែលមានរោគឃ្លង់ និង មានកូនដែលគ្រប់រៀបការ នាងត្រូវបានសង្គមបំភ្លេចចោល ហើយឱ្យរស់នៅកណ្តោចកណ្តែង។ នៅពេលនោះនិយដែលគម្រោង EIRFP បានជួបនាង ហើយចាត់ទុកថាជាគ្រួសារទុរគត។ តាមរយៈដំណើរការកសាងរបាយការណ៍ គម្រោងបានជួយនាងអភិវឌ្ឍន៍នូវយុទ្ធសាស្ត្រដើម្បីពុះពារនូវស្ថានភាពលំបាកនេះ។ នាងត្រូវបានគម្រោងផ្តល់ឱ្យចៀម២ ហើយមូលនិធិរបស់ក្រុមផ្តល់ឱ្យចៀម២ ទៀត។ ដោយបានដឹងពីសេចក្តីត្រូវការបន្ទាន់ ដើម្បីបំពេញតម្រូវការប្រចាំថ្ងៃ គេបានជួយនាងបន្ថែមទៀត ដោយផ្តល់ការងារកិន និង រែងស្រូវឱ្យនាងធ្វើសំរាប់ធានាដល់ប្រាក់ចំណូលប្រចាំថ្ងៃឱ្យនាង។

ឥឡូវនេះវាជារឿងមួយផ្សេង។ សកម្មភាពកិន និង រែងស្រូវមិនត្រឹមតែជួយនាងឱ្យរស់រានប៉ុណ្ណោះទេ ប៉ុន្តែនាងអាចសន្សំលុយបានពីរពាន់រូពីទៀតផង។ ឥឡូវនេះនាងមានចៀម ១០ក្បាល ហើយមានមុខរបររកស៊ីធំជាងមុន។ ក្រៅពីនេះនាងបានរៀបការកូននាងទៀតផង។ ហើយនាងត្រូវបានសង្គមទទួលស្គាល់។



នាង Ravati និង សត្វចៀមរបស់នាង

លោក *Binay Sahay* គឺជាអ្នកជំនាញខាងអភិវឌ្ឍន៍សង្គមធ្វើការឱ្យ *GVT* មានមូលដ្ឋាននៅស្រុក *Ranchi* រដ្ឋ *Jharkhand* យើងអាចទាក់ទងគាត់តាមរយៈអ៊ីមែល < sahaybinay@yahoo.com >.

# ពត៌មានពីទស្សនាវដ្តីរបស់ STREAM

បោះពុម្ពដោយ STREAM- Support to Regional Aquatic Resources Management
Network of Aquaculture Centres in Asia-Pacific (NACA) Secretariat
Suraswadi Building
Department of Fisheries Compound
Kasetsart University Campus
Ladyao, Jatujak, Bangkok 10903
Thailand

ក្រុមអ្នកបោះពុម្ពផ្សាយ

Kath Copley អ្នកជំនាញការខាងទំនាក់ទំនងនៃគំរោង STREAM

Graham Haylor, នាយកនៃគំរោង STREAM

Le Thanh Luu, អ្នកសំរបសំរួលជាតិនៃគំរោង STREAMនៅវៀតណាម

William Savage, អ្នកជំនាញការខាងទំនាក់ទំនងនៃគំរោង STREAM

Sonia Seville, អ្នកសំរបសំរួលជាតិនៃគំរោង STREAMនៅហ្វីលីពីន

Thay Somony, អ្នកសំរបសំរួលជាតិនៃគំរោង STREAM នៅកម្ពុជា

## គោលបំណង

ទស្សនាវដ្តីរបស់ STREAMបោះពុម្ពរៀងរាល់ត្រីមាសដើម្បីលើកកំពស់ការចូលរួម, ទំនាក់ទំនង, និង គោលនយោបាយដែលជួយដល់ជីវភាពរស់នៅអ្នកប្រើប្រាស់ធនធានវារិជាតក្រីក្រក្នុងតំបន់អាស៊ីប៉ាស៊ីភិច និង កសាងទំនាក់ទំនងក្នុងវិស័យគ្រប់គ្រងធនធានវារិជាត និង ផ្នែកផ្សេងទៀតនៅក្នុងតំបន់។ ទស្សនាវដ្តីរបស់ STREAM មានអត្ថបទដែលទាក់ទងនឹងប្រជាជនដែលការចិញ្ចឹមជីវិតរបស់ពួកគេពឹងផ្អែកលើធនធានជលផល ជាពិសេសប្រជាជនដែលមានធនធានតិចតួច អ្នកអនុវត្ត រដ្ឋាភិបាល មិនមែនរដ្ឋាភិបាល និង អន្តរជាតិ ដែលធ្វើការជាមួយពួកគេក្នុងសហគមន៍។ បញ្ហាមានដូចជា: ការរៀនសូត្រ, ការគ្រប់គ្រងជំលោះ, បច្ចេកវិទ្យាទំនាក់ទំនង និង ពត៌មាន, ការគ្រប់គ្រងធនធានវារិជាត, ច្បាប់, ការចិញ្ចឹមជីវិត, យិនឌ័, ការចូលរួម, អ្នកជាប់ពាក់ពន្ធ័, គោលនយោបាយ និង ទំនាក់ទំនង។

គោលបំណងសំខាន់មួយផ្សេងទៀតរបស់ទស្សនាវដ្តី STREAMគឺផ្តល់ឱកាសឱ្យបញ្ចេញសំលេងដែលកំរមានដើម្បីឱ្យគេបានលឺ និង មានតំណាងនៅក្នុងវិជ្ជាជីវបោះពុម្ពដែលមានបន្ថិចបន្តួចនៅក្នុងស្ថាប័នរៀនសូត្រ។ មាតិកាក្នុងទស្សនាវដ្តី មិនត្រូវយកទៅដើម្បីបញ្ជាក់ពីទស្សនះនៃអង្គការ ឬ ភ្នាក់ងារណាមួយទេ ប៉ុន្តែវាគ្រាន់តែជាគំនិតនៃ

មនុស្សម្នាក់ៗដោយផ្អែកលើបទពិសោធរបស់ពួកគេ។ អ្នកនិពន្ធទទួលខុសត្រូវលើមាតិកាអត្ថបទរបស់ពួកគេ ហើយ STREAMទទួលខុសត្រូវលើភាពលំអៀង និង លើសលួសផ្សេងៗ។

## ការចែកចាយ

ទស្សនាវដ្តីរបស់ STREAM អាចរកបានជា ៣ ទំរង់

- ជាទំរង់អេឡិចត្រូនិចដែលត្រូវបានបោះពុម្ព និង ចែកចាយដោយ មណ្ឌលទំនាក់ទំនង STREAM
- ជាទំរង់ដែលអាចរកបាន ហើយទាញមកពី Website របស់ STREAM គឺ www.streaminitiative.org
- ជាឯកសារបោះពុម្ពដែលចែកចាយដោយ លេខាធិការដ្ឋាននៃ បណ្តាញនៃមជ្ឈមណ្ឌលវារីវប្បកម្ម ក្នុងតំបន់អាស៊ីប៉ាស៊ីភិច

## ការចូលរួមចំណែក

ទស្សនាវដ្តីរបស់ STREAM លើកទឹកចិត្តដល់ការចូលរួមចំណែកជាអត្ថបទដែលទាក់ទងនឹងអ្នកប្រើប្រាស់ធនធាន វារីជាត និង មនុស្សដែលធ្វើការជាមួយពួកគេ។ ទស្សនាវដ្តីរបស់ STREAMkក៏ជួយដល់សហការីដែលធ្វើការនៅថ្នាក់សហគមន៍ដើម្បីឱ្យចងក្រងឯកសារពីបទពិសោធរបស់ពួកគេនៅក្នុងទំព័រទាំងនេះ។

អត្ថបទគួរសរសេរជាភាសាអង់គ្លេសដែលងាយយល់ ហើយមិនឱ្យលើសពី ១000 ពាក្យ (ប្រហែល ២ ទំព័រ A4)

អ្នកអាចផ្តល់ជាអត្ថបទផ្សេងៗទៅឱ្យលោក William Savage អ្នកបោះពុម្ពផ្សាយ ទស្សនាវដ្តីរបស់ STREAMតាមរយៈ savage@loxinfo.co.th.

ពត៌មានបន្ថែមសូមទាក់ទងលោក Graham Haylor នាយកនៃគំរោង STREAM តាមរយៈអ៊ីមែល ghalor@loxinfo.co.th

# ពត៌មានពី STREAM

STREAM (ជួយគាំទ្រការគ្រប់គ្រងធនធានវារីជាតក្នុងតំបន់) ជាគំរោងមួយដែលគ្រោងឡើងក្នុងរយៈ ពេល៥ឆ្នាំនៃកម្មវិធីការងាររបស់ NACA (បណ្តាញនៃមជ្ឈមណ្ឌល វារីវប្បកម្មក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិច) ។

គំរោងមានទិសដៅជួយដល់ទីភ្នាក់ងារ និងស្ថាប័នផ្សេងៗឱ្យៈ

- ប្រើប្រាស់ពត៌មានដែលមានស្រាប់ឱ្យកាន់តែមានប្រសិទ្ធិភាព
- យល់ឱ្យកាន់តែច្បាស់ថែមទៀតពីជីវភាពរបស់ប្រជាជនក្រីក្រ និង
- អាចឱ្យប្រជាជន ក្រីក្រ ប្រើប្រាស់ឥទ្ធិពលរបស់ខ្លួនលើគោលនយោបាយ និង ដំណើរការដែលជះឥទ្ធិពលលើជីវិតរបស់ពួកគេ ។

គំរោង នឹងធ្វើការងារនេះតាមរយៈការជួយអភិវឌ្ឍន៍ គោលនយោបាយ និង ដំណើរការសំរបសំរួលស្ថាប័ន និងការកសាងសមត្ថភាពដើម្បីៈ

- រកឱ្យឃើញនូវបញ្ហានៃការគ្រប់គ្រងធនធានវារីជាតដែលជះឥទ្ធិពលទៅលើជីវភាពអ្នកក្រីក្រ
- ពិនិត្យ និង វាយតំលៃលើយុទ្ធវិធីគ្រប់គ្រងផ្សេងៗគ្នា
- ផ្សព្វផ្សាយពត៌មាន
- ធ្វើបណ្តាញនៅក្នុង/រវាងវិស័យ និងរវាងប្រទេស

គំរោងគឺផ្អែកលើភាពជាដៃគូរដែលជាប់ទាក់ទងចាប់តាំងពីការករកើតនូវការរួបរួមជាដៃគូរ (DFID, VSO, FAO) ដែលជួយដល់ (NACA) ។ គំរោងនឹងទទួលយកនូវយុទ្ធវិធីសមស្របមួយដើម្បីសំរេចឱ្យបាននូវ ទំនាក់ទំនងរវាងអ្នកជាប់ពាកលពន្ធ័ទាំងអស់ដែលជាប់ទាក់ទិននិងការគ្រប់គ្រងធនធានវារីជាត និងជួយពួកគេឱ្យរួម ចំណែកក្នុងការរៀបចំ, អនុវត្តន៍ និងការគ្រប់គ្រងគំរោង ។

ការធ្វើការងាររបស់ដៃគូរត្រូវបានសំរបសំរួល នៅក្នុងប្រទេសនិមួយៗតាមរយៈក្រុមសំរបសំរួលជាតិ ដែលរួមមានៈ អ្នកសំរបសំរួលជាតិ (មន្ត្រីជាន់ខ្ពស់ដោយមានការយល់ព្រមជាមួយរដ្ឋាភិបាល) និង អ្នកគ្រប់គ្រងមណ្ឌលទំនាក់ទំនង (ជាមន្ត្រីដែលធ្វើការពេញម៉ោងហើយជួយឧបត្ថម្ភក្នុងរយៈពេល២ ឆ្នាំដំបូងដោយ STREAM) ហើយភ្ជាប់ទំនាក់ទំនងជាមួយអ្នកជាប់ពាក់ពន្ធ័ផ្សេងៗ ។ អ្នកគ្រប់គ្រងមណ្ឌលទំនាក់ទំនងត្រូវបានគេផ្តល់ឱ្យនូវ Hardware (មានដូចជា កុំព្យូទ័រ ម៉ាស៊ីនស្កេន...), Software (កម្មវិធីកុំព្យូទ័រ ដូចជា word, excel..), បំពាក់បំប៉ន, ការជួយឧបត្ថម្ភដល់បច្ចេកវិទ្យាពត៌មាន បណ្តាញ និង ធនធានមនុស្ស ហើយភ្ជាប់ជាមួយនឹងអ្នកជាប់ពាក់ពន្ធ័តាមរយៈ Internet ។

ការសំរបសំរួលជាតិគឺអនុវត្តទៅតាម អត្ថបទយុទ្ធសាស្ត្រនៃប្រទេស(CSP) ដោយមានការពិនិត្យឡើងវិញជារៀង រាល់ឆ្នាំ ហើយធ្វើឡើងដោយអ្នកសំរបសំរួល និង អ្នកគ្រប់គ្រងមណ្ឌលទំនាក់ទំនង ដោយមានការពិគ្រោះយោបល់ ជាមួយអ្នកជាប់ពាក់ពន្ធ័ ។ CSP រកឱ្យឃើញនូវបញ្ហា, ផ្តោតលើទំនាក់ទំនងក្នុងតំបន់, ធ្វើសំណើរ និង ធ្វើអាទិភាព សកម្មភាពសំខាន់ និង ស្វែងរកថវិកាសំរាប់អនុវត្តសកម្មភាពនេះពី STREAM និងពីកន្លែងផ្សេងៗទៀត ( ដោយមាន ការជួយជ្រោមជ្រែងពី STREAM ) ។

កាិរយាល័យតំបន់របស់ STREAM (នៅលេខាធិការ NACA ទីក្រុងបាងកក)ដឹកនាំគំរោង, ផ្តល់នូវតួនាទី សំរបសំរួលក្នុងតំបន់, និង មូលនិធិ និង គ្រប់គ្រងបញ្ហាដែលទាក់ទងនឹង ការចិញ្ចឹមជីវិត, ការអភិវឌ្ឍន៏គោលនយោ បាយ ទំនាក់ទំនង និង បញ្ហាពិសេសផ្សេងៗទៀត ។

ការប្រតិបត្តិរបស់ STREAM គឺជាដំណើរការដដែលៗមួយដែលធ្វើសាកល្បង នៅឆ្នាំទីមួយនៅកម្ពុជា និង វៀតណាមដែលជាកន្លែងមានឳកាសដើម្បីដោះស្រាយនូវភាពក្រីក្រ និងលើកកំពស់អភិបាលកិច្ចល្អ STREAM មានគំរោងពង្រីកទៅបណ្តាប្រទេសផ្សេងៗទៀតនៅពេលទទួលបានបទពិសោធន៏, មេរៀនត្រូវ បានរៀន, ការជះឥទ្ធិពលត្រូវបានដឹង, ហើយថវិកាបន្ថែមត្រូវបានធានា ។ យុទ្ធសាស្ត្រទំនាក់ទំនងរបស់ STREAM គឺមាន ទិសដៅជួយបង្កើនឥទ្ធិពលដោយធានាថាចំណេះដឹងដែលមានស្រាប់នៅក្នុងតំបន់ និង ជំនាញការ បានជា ពតិមានដល់ ដំណើរការផ្លាស់ប្តូរនៅក្នុងតំបន់ ហើយបទពិសោធ ត្រូវបានចែកចាយទូទាំងតំបន់អាស៊ីប៉ាស៊ីភិច ។ ទស្សនាវដ្តីរបស់ STREAM រួមជាមួយវេទិកាពិភាក្សាដែលមាននៅលើ Website គឺជាផ្នែកនៃយុទ្ធសាស្ត្រនេះ ។

អាស័យដ្ឋានទំនាក់ទំនង:
STREAM National Communications Hub Managers

Cambodia : Sem Viryak, < cfdo@camnet.com.kh >
India : Rubu Mukherjee < rubumukherjee@rediffmail.com >
Indonesia : Aniza Suspita < indostream@perikana-budidaya.go.id >
Myanmar : Khin Maung Soe < DOF@mptmail.net.com >
Nepal : Nilkanth Pokhrel < agroinfo@wlink.com.np >
Philippines : Elizabeth Gonzales < streambfar-phil@skyinet.net >
Vietnam : Nguyen Song Ha < nguyensongha@fpt.vn >
Yunan, China : Susan Li < YNYYCN@KM169.net; blueseven@mail.china.com >